សុន្ទរកថារបស់**លោក គាត់ម៉ូរ៉ា ហ៊ីរ៉ូស៊ី** ឧបទូតស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិរបស់ប្រទេសជប៉ុន

២២ កុម្ភៈ ២០១២

**សូមគោរព លោក សួស ស៊ីផៃ ប្រធានក្រុមប្រឹក្សាឃុំតាជេស!**
**សូមគោរព អស់លោក លោកស្រី!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយដើម្បីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយជាមួយក្រុមប្រឹក្សាឃុំតាជេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង សម្រាប់គម្រោងសាងសង់កំពង់ផែតាជេសក្នុងខេត្តកំពង់ឆ្នាំង។

ជំនួយនេះនឹងផ្តល់លទ្ធភាពដល់ក្រុមប្រឹក្សាឃុំតាជេសក្នុងការសាងសង់ផែបេតុងមួយ និង ពោងបណ្តែតផែនៅតាមបណ្តោយដងទន្លេសាប ដើម្បីជំនួសឲ្យកំពង់ផែចាស់ដែលធ្វើអំពីឈើ។ ជាមួយផែបេតុងថ្មីនេះ ប្រជាពលរដ្ឋ៤ឃុំដែលមានចំនួន២៨,៧២០នាក់នឹងអាចធ្វើដំណើរឆ្លងកាត់ទន្លេសាបដោយសុវត្ថិភាពពេញមួយឆ្នាំ ហើយពួកគេនឹងមិនមានការលំបាកក្នុងការធ្វើដំណើរទៅសាលារៀន និងមណ្ឌលសុខភាពទៀតឡើយ។

យើងក៏រំពឹងផងដែរថាផែបេតុងថ្មីនេះនឹងជួយជំរុញសកម្មភាពសេដ្ឋកិច្ច ក៏ដូចជាកែប្រែមុខមាត់ថ្មីសម្រាប់តំបន់ជុំវិញនោះ ដោយសារធនាគារអភិវឌ្ឍន៍អាស៊ីកំពុងផ្តល់ជំនួយដើម្បីជួសជុលផ្លូវមួយដែលតភ្ជាប់កំពង់ផែនេះជាមួយខេត្តកំពង់ស្ពឺ។

ខ្ញុំសង្ឃឹមថាគម្រោងនេះនឹងត្រូវបានអនុវត្តយ៉ាងរលូនដោយក្រុមប្រឹក្សាឃុំតាជេស ហើយនឹងត្រូវបានថែទាំយ៉ាងត្រឹមត្រូវ។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមថាគម្រោងនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាព រវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។

សូមអរគុណ!